**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:....៤៣...សសរ.ក

# សេចក្តីសំរេច

## ស្តីពីការបង្កើតក្រុមអធិការកិច្ចអន្តរក្រសួង
## ដើម្បីត្រួតពិនិត្យលើលទ្ធផលនៃការសិក្សាស្រាវជ្រាវធនធានរ៉ែរបស់ក្រុមហ៊ុនទាំងអស់
## ដែលបានទទួលគោលការណ៍រួចហើយ ពីក្រសួង-ស្ថាប័នមានសមត្ថកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យវិសោធនកម្មជាបន្តបន្ទាប់លេខ១១២ អនុក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ និងលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៥
- យោងអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ១១២ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ និងអនុក្រឹត្យ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៤
- យោងស្មារតីអង្គប្រជុំ"ច្រកចេញ-ចូលតែមួយ" នៃ ក.អ.ក"គ.វ.ក" នាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៥

## សំរេច

**ប្រការ១:** បង្កើតក្រុមអធិការកិច្ចអន្តរក្រសួង ដើម្បីត្រួតពិនិត្យលើលទ្ធផលនៃការសិក្សាស្រាវជ្រាវធនធានរ៉ែ របស់ក្រុមហ៊ុនទាំងអស់ ដែលបានទទួលគោលការណ៍រួចហើយ ពីក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **ផ្ទាត់ ហាម** | រដ្ឋលេខាធិការក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | ប្រធាន |
| ២- ឯកឧត្តម **ជា ស៊ាវហុង** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | អនុប្រធាន |
| ៣- ឯកឧត្តម **ស៊ួន សិរីឆ្នី** | អគ្គលេខាធិការ គណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ៤- ឯកឧត្តម **ញាណា ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- ឯកឧត្តម **នា ជុប** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៦- ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** | តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧- ឯកឧត្តម **មួង សៅវ៉ន** | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៨- ឯកឧត្តម **អ៊ិត ណារ៉ូ** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩- ឯកឧត្តម **គ្រួច ម៉ុនលី** | អគ្គនាយក ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ១០- ឯកឧត្តម **សុខ ឡេង** | អគ្គនាយក នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១១- គ្រប់អភិបាលខេត្ត/ក្រុងពាក់ព័ន្ធ | | សមាជិក |
| ១២- លោក **យុន ហេង** | អនុប្រធាននាយកដ្ឋានវិភាគគំរោង និងការលើកទឹកចិត្ត នៃក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ១៣- លោក **សេង សុបិន្ដា** | អនុប្រធាននាយកដ្ឋានត្រួតពិនិត្យ និងតាមដានគំរោងវិនិយោគ នៃក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា | លេខាធិការ |

សមាជិកក្រុមអធិការកិច្ចទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

**<u>ប្រការ២</u>:** ក្រុមអធិការកិច្ចអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ :

- ចុះពិនិត្យដល់ទីកន្លែង សំដៅស្វែងយល់ពីការសិក្សាស្រាវជ្រាវរបស់ក្រុមហ៊ុនរ៉ែទាំងអស់ ដែលបានទទួលគោលការណ៍រួចហើយ ពីក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដោយចាប់ផ្ដើមមុនគេពីក្រុមហ៊ុនរ៉ែនៅតំបន់ស្រុករវៀង ខេត្តព្រះវិហារ ។
- ស្វែងយល់ពីមូលហេតុនៃការយឺតយ៉ាវក្នុងការប្រគល់ទីតាំងរ៉ែគ្មានសកម្មភាព ឬមានសកម្មភាពតិចតួចជូនក្រុមហ៊ុន Cambodia Iron and Steel Mining Industry Group.នេះ តាមការសំរេចកន្លងមករបស់សម្ដេចសហប្រធាន "ក.អ.ក" ដើម្បីមានវិធានការជំរុញការអនុវត្តអោយបានឆាប់ក្នុងទិសដៅជួយបង្កលក្ខណៈសម្បត្តិអោយក្រុមហ៊ុននេះ អាចជំរុញការវិនិយោគជាគញ្ចប់( រោងចក្រស្លដែក-រោងចក្រផលិតអគ្គិសនី-សាងសង់ផ្លូវរថភ្លើង-សាងសង់កំពង់ផែ.....) បាន ។
- រាយការណ៍ពីលទ្ធផល នៃការត្រួតពិនិត្យជាក់ស្ដែង នៅតាមការដ្ឋានស្រាវជ្រាវរ៉ែ របស់ក្រុមហ៊ុននីមួយៗ ជូន "ច្រកចេញ-ចូលតែមួយ" របស់ "ក.អ.ក" ដើម្បីពិនិត្យ និងផ្ដល់មតិជូនរាជរដ្ឋាភិបាលធ្វើការសំរេច ។

**ប្រការ៣:** គ្រប់សមាសភាពនៃក្រុមអធិការកិច្ចអន្តរក្រសួង មានសិទ្ធិនាំយកទៅជាមួយ នូវមន្ត្រីបច្ចេកទេសជំនាញ ដោយគ្រាន់តែមានលិខិតឧទ្ទេសនាមពីប្រធានស្ថាប័នរបស់ខ្លួនបន្ថែមប៉ុណ្ណោះ នៅពេលចុះបំពេញបេសកកម្ម ។

**ប្រការ៤:** ក្រុមអធិការកិច្ចអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រា និងកញ្ចប់ថវិការបស់ក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា សំរាប់អនុវត្តការងារ ។

**ប្រការ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី - សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច - រដ្ឋមន្ត្រីក្រសួងបរិស្ថាន - រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល - រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម - រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ - សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា - រដ្ឋមន្ត្រីគ្រប់ក្រសួង - គ្រប់ប្រធានស្ថាប័ន - គ្រប់ខេត្ត/ក្រុង ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀង១ខ្លួន អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី សហប្រធាន "ក.អ.ក"
- ខុទ្ទកាល័យសម្តេចក្រុមព្រះ សហប្រធាន "ក.អ.ក"
- ដូចប្រការ៥ "**ដើម្បីអនុវត្ត**"
- ឯកសារ-កាលប្បវត្តិ